ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សត្យាព្រហ្មទណ្ឌ
លេខ:១១៨០/១៣-១២-២០១១
សាលដីកា
លេខ:១១៥ ក្រ.ឧ.ក/៣១-១២-២០១២

អាចនាមប្រជារាស្ត្រខ្មែរ
សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍រឿងព្រហ្មទណ្ឌលេខ:១១៨០ចុះថ្ងៃទី១៣-១២-២០១១រវាង៖

-ជនជាប់ចោទ:

១-ឈ្មោះ [redacted] វង់ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបររកស៊ីធ្វើស្រែ ទីកន្លែងកំណើត ភូមិភ្នំក្រង់ក ជំរុំសាយអេត ព្រំដែនខ្មែរថៃ និង ទីលំនៅសព្វថ្ងៃ [redacted] ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] នៅលីវ ទោសពីមុនគ្មាន។ ចាប់-ឃុំខ្លួនថ្ងៃទី១៧-៥-២០១១

២-ឈ្មោះ [redacted] សុផល ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបររកស៊ីធ្វើស្រែ កំរិតវប្បធម៌មិនចេះអក្សរ ទីកន្លែងកំណើតភូមិត្រាំកន្ទេល ស្រុកឧដុង្គ ខេត្តកំពង់ឆ្នាំង មានទីលំនៅសព្វថ្ងៃ [redacted] ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] នៅលីវ ទោសពីមុនគ្មាន។ ចាប់-ឃុំខ្លួនថ្ងៃទី១៧-៥-២០១១

៣-ឈ្មោះ [redacted] សឹងភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបររកស៊ីធ្វើស្រែ កំរិតវប្បធម៌ថ្នាក់ទី២ថ្មី ទីកន្លែងកំណើត ជំរុំសាយប៊ី ព្រំប្រទល់ខ្មែរ ថៃ មានទីលំនៅសព្វថ្ងៃ [redacted] ឪពុកឈ្មោះ [redacted] សឹម ស ម្តាយឈ្មោះ [redacted] ហៀក នៅលីវ ទោសពីមុនគ្មាន។គេចខ្លួន

ត្រូវចោទពីបទ: បង្ករបួសដោយចេតនាមានអាវុធ និង រំលោភសេពសន្ថវៈ ប្រព្រឹត្តិនៅភូមិចាមរអាឃុំព្រៃស្វាយ ស្រុកមោងឫស្សី ខេត្តបាត់ដំបងកាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៣ បទល្មើសព្រហ្មទណ្ឌមាន/៤



ផ្លូវសម្តេចសុធារស សាលាឧទ្ធរណ៍-មហាអយ្យការ (ទល់មុខព្រះបរមរាជវាំង ក្នុងបរិវេណក្រសួងយុត្តិធម៌)

Scanned with CamScanner

ចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៨១ ច្បាប់ព្រហ្មទណ្ឌអន្តរកាលនិងមាត្រា៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ៨៨ឆ្នាំ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃ [redacted]។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ភេទស្រី អាយុ២៩ឆ្នាំ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិ [redacted]។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ភេទប្រុស អាយុ២៥ឆ្នាំ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃ [redacted]។

## ឯរឿងហេតុមានដូចតទៅៈ

តាមរបាយការណ៍របស់សមត្ថកិច្ចបញ្ជាក់ថា កាលពីថ្ងៃទី២៧-១០-២០០៣ វេលាម៉ោង៨ជិតភ្លឺ ជនរងគ្រោះឈ្មោះ[redacted]រី ភេទ ស្រី ,ឈ្មោះ [redacted]ទូច ភេទស្រី និង ឈ្មោះ [redacted]លាន ភេទ ប្រុស បាននាំគ្នាដើរមកពីមើលគេរាំបាស់និងមើលកុននៅវត្តចាមរអាដើម្បីទៅផ្ទះវិញ ហើយដើរមកដល់ចំណុចអាងចាយវ៉ាយ ក្នុងភូមិចាមរអា ស្រាប់តែជនល្មើស៣នាក់ ១.ឈ្មោះ[redacted] វង់ ភេទប្រុស ២.ឈ្មោះ [redacted] សុផល ភេទប្រុស ៣.ឈ្មោះ [redacted] សឹង ភេទប្រុស មានទីលំនៅភូមិចាមរអា ឃុំព្រៃស្វាយ ស្រុកមោងឬស្សី ស្លៀកតែខោលីអូ បានពួនស្ទាក់ជនរងគ្រោះទាំងបីនាក់។ ពេលនោះជនល្មើសម្នាក់បានវាយឈ្មោះ[redacted]លានមួយដំបងបណ្តាលឲ្យធ្លាក់ទឹក ឯជនរងគ្រោះឈ្មោះ [redacted] រី ត្រូវជនល្មើស២នាក់រំលោភ ម្តងម្នាក់ៗ រហូតបានសម្រេច និងជនល្មើសម្នាក់ទៀតចាប់រំលោភជនរងគ្រោះឈ្មោះ [redacted]ទូច រហូតបានសំរេច ពេលនោះជនរងគ្រោះបានស្រែកឲ្យគេជួយទើបជនល្មើសរត់គេចខ្លួនតែម្តង ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខៈ៧១"ឃ" ចុះថ្ងៃទី ០៧-០៧-២០០៥ របស់សាលាដំបូងខេត្តបាត់ដំបង ដែលមានខ្លឹមសារដូចតទៅៈ

១-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះៈ

ក/-[redacted]វង់ ភេទ ប្រុស អាយុ ២០ឆ្នាំ សញ្ជាតិខ្មែរ

ខ/-[redacted]សុផល ភេទ ប្រុស អាយុ ២១ឆ្នាំ សញ្ជាតិខ្មែរ

គ/- [redacted] សឹង ភេទ ប្រុស អាយុ ១៩ ឆ្នាំ សញ្ជាតិខ្មែរ

ដាក់ពន្ធនាគារសរុបកំណត់១២ឆ្នាំគត់ក្នុងម្នាក់ៗ គិតពីថ្ងៃចាប់ខ្លួនបានមកទទួលទោស

ពីបទៈ បង្ករបួសដោយចេតនា និង រំលោភសេពសន្ថវៈ

ប្រព្រឹត្តនៅភូមិចាមរអា ឃុំព្រៃស្វាយ ស្រុកមោងឬស្សី ខេត្តបាត់ដំបង កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ ២០០៣។

បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៨១ច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ និង មាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសក្នុងបទឧក្រិដ្ឋ។

២-បង្គាប់ឲ្យជនជាប់ចោទឈ្មោះ[redacted]វង់ ,[redacted]សុផល ននិង [redacted]សឹង រួមគ្នាសងសំណងជម្ងឺចិត្តជាប្រាក់សរុប ៣.០០០.០០០៛០០( បីលានរៀលគត់ ) ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីរដ្ឋប្បវេណី ឈ្មោះ [redacted]ផល និង ៥០០.០០០៛០០( ហាបសិបម៉ឺនគត់ ) ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted]លាន សំណូមពរលើសពីនេះរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបដិសេធចោល ។

៣-សាលក្រមនេះចូលជាស្ថាពរហើយ បើចាប់ជនជាប់ចោទទាំងបីនាក់បាន ហើយជនជាប់ចោទទាំងបីនាក់នេះរឹងរូសពុំព្រមបង់ប្រាក់សំណងដូចបានកំណត់ក្នុងចំណុចលេខ២ទេនោះ ត្រូវបង្ខំដាក់គុកបង្ខំរូបកាយ តាមមាត្រាទី៧ និង៨ នៃច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយ ក្នុងរឿងព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើតាមក្រឹត្យ លេខៈ ១៨ ក្រ ចុះថ្ងៃទី៨ ខែ កុម្ភៈឆ្នាំ ១៩៩២ របស់ក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជា ។ /ទ



Scanned with CamScanner

៤-សាលក្រមនេះជំនុំជម្រះជាសម្ងាត់ និងប្រកាសជាសាធារណៈកំបាំងមុខជនជាប់ចោទ ,ដើមបណ្តឹងរដ្ឋប្បវេណី និង ជនរងគ្រោះបើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្តឹងទាស់ឈ្មោះ [redacted]វង់ និង ឈ្មោះ [redacted]សុផល ចុះថ្ងៃទី ៣០ ខែឧសភា ឆ្នាំ ២០១១ ប្តឹងទាស់និងសាលក្រមព្រហ្មទណ្ឌលេខ: ៧១ "យ" ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៥ ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ: ១១០ "ក" ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់សាលាដំបូងខេត្ត បាត់ដំបង បានសម្រេចដូចតទៅ ៖

១/ ទទួលបណ្តឹងទាស់ចុះថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០១១ របស់ឈ្មោះឈា វង់ និង ឈ្មោះ[redacted]សុផល ទុកជាត្រឹមត្រូវតាមទម្រង់នឹងគតិច្បាប់ ។

២/ ឲ្យជនជាប់ចោទរួចផុតពីបទចោទប្រកាន់

ក.ឈ្មោះ [redacted]វង់ ភេទប្រុស អាយុ ២០ ឆ្នាំ សញ្ជាតិខ្មែរ

ខ.ឈ្មោះ [redacted] សុផល ភេទប្រុស អាយុ ២១ ឆ្នាំ សញ្ជាតិខ្មែរ

គ.ឈ្មោះ [redacted] សឹង ភេទប្រុស អាយុ ១៩ ឆ្នាំ សញ្ជាតិខ្មែរ

ពីបទ: បង្ករបួសដោយចេតនាមានអាវុធនិងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិចាមអោ ឃុំព្រៃស្វាយ ស្រុកមោងឬស្សី ខេត្តបាត់ដំបង កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៣ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោស តាមបញ្ញត្តិតាមមាត្រា៤១ ច្បាប់ព្រហ្មទណ្ឌអន្តរកាលនិងមាត្រា៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

៣/បង្គាប់ឲ្យដោះលែងជនជាប់ចោទ ០២ រូប បើមិនមានការឃុំខ្លួនពីបទល្មើសផ្សេងទៀតទេ ។

៤/បញ្ឈប់ដីកាបង្គាប់ចាប់ខ្លួនឈ្មោះ [redacted] សឹង ភេទប្រុស អាយុ១៨ឆ្នាំ តាមដីកាលេខ:២៤៦ ដចខ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៤ ។

៥/សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះឈា វង់ , ឈ្មោះ[redacted] សុផល និងជនរងគ្រោះឈ្មោះ [redacted]រី កំបាំងមុខជនជាប់ចោទឈ្មោះ[redacted]សឹង , ដើមបណ្តឹងឈ្មោះ[redacted]ផល,[redacted]ទូច ,[redacted] ណាន និង ជនរងគ្រោះឈ្មោះ [redacted] ជឿន ។

ទុកសិទ្ធិប្តឹងទាស់ និង ឧទ្ធរណ៍តាមកំនត់ច្បាប់ ។

-បានឃើញសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍ថ្ងៃទី ០៨-១១-២០១១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ: ១១០ "ក" ចុះថ្ងៃទី០៨-១១-២០១១របស់សាលាដំបូងខេត្តបាត់ដំបងត្រង់ចំណុចសេចក្តីសម្រេចនៃសាលក្រមទាំងមូល។

-បានឃើញរបាយការណ៍ ចុះថ្ងៃទី២៤-០៣-២០១២ របស់ចៅក្រមសាលាឧទ្ធរណ៍។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

**នាពេលសវនាការ**

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ផល,ឈ្មោះ [redacted]ទូច,ឈ្មោះ [redacted] ណាន(អវត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted]វង់,ឈ្មោះ[redacted]សុផល,ឈ្មោះ [redacted]សឹង(អវត្តមាន)

ប្រធានក្រុមប្រឹក្សា: បញ្ជាក់អង្គហេតុនៃរឿង

ក្រឡាបញ្ជី:អានចម្លើយជនរងគ្រោះ,ជនជាប់ចោទ

តំណាងមហាអយ្យការផ្តល់សេចក្តីសន្និដ្ឋាន:តាមការកត់សំគាល់ពីនីតិវិធីសាលាដំបូងលើបណ្តឹងទាស់ បានសំរេចឲ្យជនជាប់ចោទម្នាក់ដែលពុំបានប្តឹងទាស់រួចផុតពីបទចោទប្រកាន់ គឺមានការខុសឆ្គង ។ ដោយឡែកតាមអង្គហេតុដែលព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍មកដោយសារឲ្យជនជាប់ចោទរួចផុតបទចោទ មិនសមនិងការប្រព្រឹត្តដែលបង្កឲ្យមានការខូចខាតនៃអំពើព្យសនកម្មដល់សង្គម។

សុំសភាព្រហ្មទណ្ឌតម្កល់សាលក្រមសាលាដំបូង លើកដំបូង ។

មេធាវីការពារជនជាប់ចោទផ្តល់សេចក្តីសន្និដ្ឋាន:សុំតម្កល់សាលក្រមប្តឹងទាស់



Scanned with CamScanner

-ក្រោយពីបានស្តាប់ការអានចម្លើយជនជាប់ចោទ,ជនរងគ្រោះ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
-ក្រោយពីបានពិនិត្យពិចារណា និងពិភាក្សាល្អិតល្អន់ត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា**

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៨-១១-២០១១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ: ១១០ "ក" ចុះថ្ងៃទី០៨-១១-២០១១ របស់សាលាដំបូងខេត្តបាត់ដំបង ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន ។

២-តាមកំណត់ហេតុនាសវនាការនៅសាលាដំបូង ជនជាប់ចោទទាំងពីរអះអាងថា មានវត្តមាននៅកន្លែងកើតហេតុ ហើយលឺសម្លេងស្រែកបានរត់ទៅមើល តែពុំបានប្រព្រឹត្តទេ គឺឈ្មោះសឹងជាអ្នកប្រព្រឹត្ត ។ ជនរងគ្រោះឈ្មោះ [redacted]រី ដែលត្រូវជាមិត្តភ័ក្តរបស់ឈ្មោះ [redacted]សុផល បានតែប្រែចម្លើយថា ឈ្មោះ[redacted]សឹង ជាប្រព្រឹត្ត មិនមែនពីនាក់នៅចំពោះមុខនេះទេ ។

៣- តាមចម្លើយរបស់ឈ្មោះ [redacted]រី នៅចំពោះមុខចៅក្រមស៊ើបសួរ( ឯកសារលេខៈ ១៩ ) បានឆ្លើយច្បាស់ថា ឈ្មោះផល ជាអ្នករំលោភ ហើយមិត្តភ័ក្តគេម្នាក់ទៀតបានចាប់រំលោភដែរ ដែលជាចម្លើយដូចគ្នានឹងកំណត់ហេតុបណ្តឹង(ឯកសារលេខ៤) អាចជឿបានថា ជនជាប់ចោទទាំងបីពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ ។

៤-សាលក្រមសាលាដំបូងដែលសម្រេចឲ្យជនជាប់ចោទទាំង៣រួចផុតពីបទចោទប្រកាន់ បានសម្រេចមិនត្រឹមត្រូវ គប្បីបដិសេធចោល ។ ម្យ៉ាងទៀតឈ្មោះ [redacted] សឹង ពុំបានដាក់ពាក្យប្តឹងទាស់ទេ ប៉ុន្តែសាលក្រមបានលើកយកមកជម្រះហើយសម្រេចឲ្យរួចផុតពីបទចោទ ។

៥-ក្រមព្រហ្មទណ្ឌបានចូលជាធរមាន ហើយបទល្មើសនេះបានផ្តល់ផលប្រយោជន៍ដល់ជនជាប់ចោទ គប្បីអនុវត្តតាមបញ្ញត្តិក្រមថ្មី តាមមាត្រា ១០,២១៧,២៣៩,២៤០ ។

**វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៨-១១-២០១១ របស់តំណាងអយ្យការអមសាលាដំបូងខេត្ត បាត់ដំបងទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២- បដិសេធចោលសាលក្រមព្រហ្មទណ្ឌលេខ: ១១០ "ក" ចុះថ្ងៃទី ០៨-១១-២០១១ របស់សាលាដំបូងខេត្តបាត់ដំបង ។

៣-តម្កល់សាលក្រមព្រហ្មទណ្ឌកំបាំងមុខលេខ: ៧១ "ឃ" ចុះថ្ងៃទី០៧-០៧-២០០៥ របស់សាលាដំបូងខេត្តបាត់ដំបងទុកជាបានការ លើកលែងតែចំណុចទី១ នៃសេចក្តីសម្រេចត្រង់ផ្តន្ទាទោសជនជាប់ចោទ ម្នាក់១១២ឆ្នាំ ត្រូវកែប្រែជា "ផ្តន្ទាទោសជនជាប់ចោទឈ្មោះ ឈា វង់ ,ឈ្មោះ [redacted] សុផល ,ឈ្មោះ [redacted] សឹង ក្នុងម្នាក់១០៧ឆ្នាំ ( ប្រាំពីរឆ្នាំគត់ ) តាមមាត្រា ១០,២១៧,២៣៩,២៤០ នៃក្រមព្រហ្មទណ្ឌ ។

ចំណុចដទៃទៀតនៅរក្សាទុកជាបានការដដែល ។

៤-បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។/.



Scanned with CamScanner

សាលដីកានេះ ជំនុំជំរះចំពោះមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ ប្រកាសជាសាធារណៈ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ បើកសិទ្ធិប្ដឹងទាស់និងប្ដឹងសាទុក្ខក្នុងរយៈពេលដែលច្បាប់កំណត់ ។

សាលដីកានេះ ចូលជាស្ថាពរលើជនជាប់ចោទឈ្មោះ [redacted] វង់ និងឈ្មោះ [redacted] សុផល ។

សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកានិងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកំលាំងប្រដាប់អាវុធគ្រប់ថ្នាក់ គ្រប់តំណែងជួយសហការអនុវត្តសាលដីកានេះអោយបានសម្រេចបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជំរះ** |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី១៨ ខែមិនា ឆ្នាំ២០១៤

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានសាលាឧទ្ធរណ៍**

[redacted]



Scanned with CamScanner